អត្ថប្រយោជន៍បេឡាសន្តិសុខសង្គម និងមូលនិធិសំណង់ពលកម្ម



បេឡាសន្តិសុខសង្គម

គឺជាមូលនិធិដែលបង្កើតឡើងដោយរដ្ឋាភិបាល ដើម្បីបង្កើតស្ថិរភាព និងការធានាសម្រាប់សមាជិក ដោយធ្វើការបង់ប្រាក់ទៅឲ្យមូលនិធិកណ្តាល ដែលមានអ្នកដែលទទួលបានការធានាគឺខ្លួនយើងផ្ទាល់ ក្រុមហ៊ុនឬថៅកែ និងរដ្ឋាភិបាលបង់ប្រាក់ទាំងអស់គ្នា។

អ្នកទទួលបានការធានាមានប្រភេទ...?

អ្នកបង់ប្រាក់ចូលរួមវិភាគទាន ដែលបណ្តាលឱ្យមានសិទ្ធិទទួលអត្ថប្រយោជន៍ជំនួសមកវិញ និងមាន ៣ ប្រភេទ។

១. អ្នកទទួលបានការធានាតាមមាត្រា ៣៣
២. អ្នកទទួលបានការធានាតាមមាត្រា ៣៩
៣. អ្នកទទួលបានការធានាតាមមាត្រា ៤០

ការរួមចំណែកបង់ប្រាក់ចូលរួម ច្បាប់អនុញ្ញាតឲ្យភាគីទាំង ៣ បង់ប្រាក់ចូលមូលនិធិដូចខាងក្រោម៖

% ប្រាក់ឈ្នួលនៃការការពារ	រដ្ឋាភិបាល	ថៅកែឬក្រុមហ៊ុន	អ្នកទទួលបានការធានា (១៥,០០០)	សរុប	ចំណាំ
ឈឺ ១.០៦ សំរាលកូន ០.២៣ ពិការ ០.១៣ ស្លាប់ ០.០៨ សរុប ៤ ករណី	១.៥	១.៥	១៥៩.០០ ៣៤.៥០ ១៩.៥០ ១២ ១.៥	២២៥ ៤.៥	មិនឲ្យវិញ
ប្រាក់ឧបត្ថម្ភកូន, ជរាភាព	១.០០	៣.០០	៣.០០ ៤៥០	៧.០០	ឲ្យមកវិញ - ប្រាក់ដុំ - ប្រចាំខែ
គ្មានការងារ	០.២៥	០.៥០	០.៥០ ៧៥	១.២៥	មិនឲ្យវិញ
សរុប	២.៧៥	៥.០០	៥.០០	១២.៧៥	

តើនឹងទទួលបានសិទ្ធិទាំងនេះនៅពេលណា?

១. ករណីឈឺ

បង់ប្រាក់ចូលរួម ៣ខែ ក្នុងរយៈពេល ១៥ ខែ មុនខែនៃការទទួលសេវាវេជ្ជសាស្ត្រ។



២. ករណីសម្រាលកូន

បង់ប្រាក់ចូលរួម ៥ខែ ក្នុងរយៈពេល ១៥ ខែ មុនខែសម្រាលកូន។

៣. ករណីពិការ

បង់ប្រាក់ចូលរួម ៥ខែ ក្នុងរយៈពេល ១៥ ខែ មុនខែដែលពិការ។

៤. ករណីស្លាប់

បង់ប្រាក់ចូលរួម ១ខែ ក្នុងរយៈពេល ៦ ខែ មុនខែដែលស្លាប់។

៥. ករណីឧបត្ថម្ភកូន

បង់ប្រាក់ចូលរួម ១២ខែ ក្នុងរយៈពេល ៣៦ ខែ មុនខែដែលទទួលបានសិទ្ធិ។

៦. ករណីគ្មានការងារ

បង់ប្រាក់ចូលរួម ៦ខែ ក្នុងរយៈពេលល ១៥ ខែ មុនពេលគ្មានការងារធ្វើជាមួយថៅកែចុងក្រោយ។

៧. ករណីចាស់ជរា

តាមរយៈពេលបង់ប្រាក់ចូលរួម

១. ប្រាក់សោធននិវត្តន៍អាយុចាស់ បង់រំភាគទានតិចជាង ១៨០ ខែ

២. ប្រាក់សោធននិវត្តន៍អាយុចាស់ បង់រំភាគទានចាប់ពី ១៨០ ខែ ឬច្រើនជាងនេះ។

១.ករណីគ្រោះថ្នាក់ ឬឈឺ

បង់ប្រាក់ចូលរួម ៣ខែ ក្នុងរយៈពេល ១៥ ខែ មុនខែនៃការទទួលសេវាវេជ្ជសាស្ត្រ។

សេវាផ្នែកពេទ្យ

សំណងសម្រាប់ការបាត់បង់ប្រាក់ចំណូលថ្លៃសរីរាង្គសិប្ប

និម្មិត និងឧបករណ៍ពេទ្យ

ការព្យាបាលធ្មេញ

សេវាផ្នែកពេទ្យ

ទទួលការព្យាបាលនៅមន្ទីរពេទ្យ
ដែលកំណត់សិទ្ធិដោយការិយាល័យសន្តិសុខសង្គម។

ដោយឥតគិតថ្លៃ គ្មានដែនកំណត់លើចំនួនដង។

អ្នកទទួលបានការធានា អាចស្នើសុំផ្លាស់ប្តូរមន្ទីរពេទ្យចាប់ពី ១ មករាដល់ថ្ងៃទី ៣១ មីនាជារៀងរាល់ឆ្នាំ។

១៤ ជំងឺ
ដែលមិនត្រូវបានធានារ៉ាប់រង



១. ការព្យាបាលអ្នកញៀនថ្នាំ លើកលែងតែការប្រើមេតាដូនសម្រាប់ព្យាបាល។

២. ការព្យាបាលជំនួសក្រលៀន លើកលែងតែ ការខ្សោយក្រលៀនដំណាក់កាលចុងក្រោយ ពួកគេមានសិទ្ធិទទួលបានការលាងឈាម ការលាងឈាមតាមរន្ធគូថ និងការប្តូរក្រលៀន។

៣. ជំងឺដូចគ្នាដែលព្យាបាលលើសពី ១៨០ ថ្ងៃក្នុងមួយឆ្នាំ លើកលែងតែមានការយល់ព្រមពីមន្ទីរពេទ្យតាមសិទ្ធិ ហើយការិយាល័យសន្តិសុខសង្គមបង់ប្រាក់សេវាព្យាបាលទៅមន្ទីរពេទ្យ (ក្នុងករណីលើស ១៨០ ថ្ងៃ) តាមលក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌ និងអត្រាសេវា។

៤. សកម្មភាពណាមួយដើម្បីភាពស្រស់ស្អាតដោយគ្មានសញ្ញាវេជ្ជសាស្ត្រ។

៥. ការព្យាបាលដែលស្ថិតក្នុងការពិសោធន៍

៦. ការព្យាបាលភាពគ្មានកូន

៧. ការធ្វើកោសល្យវិច័យ សម្រាប់ការវះកាត់ប្តូរសរីរាង្គ លើកលែងតែការធ្វើកោសល្យវិច័យសម្រាប់ការប្តូរខួរឆ្អឹង

៨. ការពិនិត្យណាមួយដែលលើសពីការចាំបាច់

៩. ការវះកាត់ប្តូរសរីរាង្គ លើកលែងតែការប្តូរខួរឆ្អឹង ការប្តូរកែវភ្នែក ការព្យាបាលជំនួសក្រលៀន បេះដូង សួត ថ្លើម ការប្តូរលំពែង និងក្នុងករណីមានការប្តូរសរីរាង្គច្រើនជាងមួយក្នុងពេលដំណាលគ្នា។

១០. ការផ្លាស់ប្តូរភេទ

១១. ការបណ្តុះសិប្បនិម្មិត

១២.សេវាកំឡុងពេលស្តារនីតិសម្បទា

១៣. ទន្តសាស្ត្រ លើកលែងតែការដកធ្មេញ ការបំពេញ ការកោសកំបោរធ្មេញ ការជាក់ធ្មេញសិប្បនិមិត្តដែលអាចដកចេញបាន(ដោយផ្នែក/ពេញមាត់)។

១៤. វ៉ែនតា លើកលែងតែកញ្ចក់កែវភ្នែកដែលប្រើបន្ទាប់ពីការវះកាត់យកកែវភ្នែកចេញដើម្បីព្យាបាលជំងឺភ្នែកឡើងបាយ។

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

គ្រោះថ្នាក់/ឈឺបន្ទាន់មិនអាចព្យាបាលតាមបំណុាដែលយើងមានសិទ្ធិ

អាចទទួលការព្យាបាលបាននៅគ្រប់មន្ទីរពេទ្យ ដោយការិយាល័យសន្តិសុខសង្គមជាអ្នកចំណាយទៅឲ្យមុនសិនលើការព្យាបាលដែលកើតឡើងក្នុងរយៈពេល ៧២ ម៉ោង បន្ទាប់ពីបានទទួលការព្យាបាល (មិនរាប់បញ្ចូលថ្ងៃឈប់សម្រាក) ថ្ងៃឈប់សម្រាកសាធារណៈ
ហើយអាចបើកប្រាក់វិញតាមអត្រាដែលបានបញ្ជាក់។

មន្ទីរពេទ្យរដ្ឋ

អ្នកជំងឺមិនដេកពេទ្យ ⟹ បង់សងតាមការពិតនិងតម្រូវការ
អ្នកជំងឺដេកពេទ្យ ⟹ បង់សងតាមតម្រូវការក្នុងរយៈពេល ៧២ម៉ោង ថ្លៃបន្ទប់និងអាហារមិនលើសពី ៧០០ បាតក្នុងមួយថ្ងៃ។

មន្ទីរពេទ្យឯកជន

អ្នកជំងឺមិនដេកពេទ្យ

សេវាព្យាបាលតាមការចំណាយពិតមិនលើស ១000 បាត
ថ្លៃពិនិត្យពិសេស (តាមកាលវិភាគ)

អ្នកជំងឺដេកពេទ្យ (ក្នុងរយៈពេល ៧២ម៉ោង)

ថ្លៃព្យាបាល	មិនលើស	២000 បាត/ថ្ងៃ
ថ្លៃបន្ទប់ និងអាហារ		៧00 បាត/ថ្ងៃ
ថ្លៃព្យាបាលក្នុងបន្ទប់ អាយស៊ីយូ		៤,៥00 បាត/ថ្ងៃ
ការវះកាត់ធំ	មិនលើស 1 ម៉ោង	៨,000 បាត
	លើស ១ ម៉ោង	១,២000 បាត
	២ ម៉ោងឡើង	១,៦000 បាត
ការធ្វើអោយរស់ឡើងវិញ		៤,000 បាត
ពិនិត្យមន្ទីរពិសោធន៍/ឬអិចសារេកាំរស្មីអ៊ុច		១,000 បាត

ថ្លៃពិនិត្យពិសេស (តាមកាលវិភាគ)



ករណីគ្រោះថ្នាក់អន្តរាយ ឬឈឺបន្ទាន់ធ្ងន់ធ្ងរ
យូសឹប(UCEP) អ្នកទទួលបានការធានា មានសិទ្ធិគ្រប់កន្លែង

អាចទទួលការព្យាបាលនៅមន្ទីរពេទ្យ

ទាំងមន្ទីរពេទ្យរដ្ឋ និងឯកជន ដែលនៅជិតបំផុតដោយមិនគិតថ្លៃ។ ការិយាល័យសន្តិសុខសង្គមនឹងទទួលខុសត្រូវលើការចំណាយរហូតដល់ភាពធ្ងន់ធ្ងរនោះបានបញ្ចប់ក្នុងរយៈពេល ៧២ ម៉ោង។



អ្នការៈអាសន្នធ្ងន់ធ្ងរទាំង ៦ ដែលប៉ះពាល់ដល់ជីវិត និងសរីរាង្គសំខាន់ៗ

១. សន្លប់, មិនដឹងខ្លួន, មិនដកដង្ហើម
២. ដកដង្ហើមលឿន ថប់ដង្ហើមធ្ងន់ធ្ងរ ដង្ហើមខ្លីស្នុះ
៣. ឈឺទ្រូងភ្លាមៗធ្ងន់ធ្ងរ
៤. ឡើងពុះ បែកញើស ត្រជាក់ខ្លួន ឬប្រកាច់
៥. ដៃជើងទន់ខ្សោយមួយចំហៀង និយាយមិនច្បាស់ភ្លាមៗ ឬប្រកាច់ជាបន្តបន្ទាប់មិនឈប់
៦. មានរោគសញ្ញាផ្សេងទៀតដែលប៉ះពាល់ដល់ប្រព័ន្ធដកដង្ហើម ចង្វាន្តឈាមវត្ត និងខួរក្បាលដែលអាចគំរាមកំហែងដល់អាយុជីវិត។

ជំងឺធ្ងន់ធ្ងរ មានសិទ្ធិនៅគ្រប់ទីកន្លែង "UCEP" ១៦៦៩

ករណីគ្រោះថ្នាក់អន្តរាយ ឬឈឺបន្ទាន់ធ្ងន់ធ្ងរ
អ្នកទទួលយូសិប(UCEP)លបានការធានា មានសិទ្ធិគ្រប់កន្លែង

១. ស្នើសុំប្រើប្រាស់សិទ្ធិ យូសិប UCEP

២. មន្ទីរពេទ្យឯកជនវាយតម្លៃជំងឺសង្គ្រោះបន្ទាន់តាមការណែនាំរបស់វិទ្យាស្ថានជាតិវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់។

៣. មន្ទីរពេទ្យឯកជនវាយតម្លៃអ្នកជំងឺ និងជូនដំណឹងលទ្ធផលនៃការវាយតម្លៃដល់អ្នកជំងឺ ឬសាច់ញាតិ។

៤. មានសិទ្ធិសម្រាប់ជំងឺធ្ងន់ធ្ងរ ទទួលការព្យាបាលតាមសិទ្ធិ យូសិប UCEP

៥. មិនមានសិទ្ធិសម្រាប់ជំងឺបន្ទាន់ អ្នកជំងឺមានសិទ្ធិទទួលការព្យាបាលតាមសិទ្ធិរបស់ពួកគេទៅតាមមូលនិធិដែលមាន។

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT



ការព្យាបាលធ្មេញ

១. ក្នុងករណីដក បំពេញ កោសសំអាតធ្មេញ និង ការវះកាត់ធ្មេញ មិនលើសពី ៩០០ បាតក្នុង មួយឆ្នាំ

១. ទទួលសេវានៅមណ្ឌលសុខភាពដែលមានកិច្ចព្រមព្រៀងជាមួយការិយាល័យសន្តិសុខសង្គម មិនចាំបាច់ចាយលុយជាមុន។

២. ចាយលុយជាមុនសិន ហើយអាចបើកវិញបាននៅការិយាល័យសន្តិសុខសង្គម ទូទាំងប្រទេស។

២. ក្នុងករណីដាក់ធ្មេញសប្បនិមិត្ត ដែលអាចដកចេញបានផ្នែកខ្លះក្នុងរយៈពេល ៥ ឆ្នាំ

- ១-៥ ធ្មេញ មិនលើសពី ១,៣០០ បាត
- លើសពី ៥ ធ្មេញ មិនលើសពី ១,៥០០ បាត

៣. ក្នុងករណីដកធ្មេញសរុបក្នុងរយៈពេល ៥ឆ្នាំ

- ធ្មេញដកបានទាំងខាងលើ ឬខាងក្រោម មិនលើសពី ២,៤០០បាត
- ធ្មេញដកបានទាំងមាត់ខាងលើ និងខាងក្រោម តម្លៃមិនលើស ៤,៤០០បាត

ធ្វើធ្មេញ "ឥតគិតថ្លៃ" មិនចាំបាច់បង់ប្រាក់ជាមុន

ទទួលសេវាក្នុងមន្ទីរពេទ្យ/គ្លីនិកដែលបានធ្វើកិច្ចព្រមព្រៀងជាមួយការិយាល័យសន្តិសុខសង្គម។

មិតรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

ការពិនិត្យសុខភាព

ទទួលសេវាពិនិត្យសុខភាពពី មន្ទីរពេទ្យដែលចូលរួម ដោយឥតគិតថ្លៃ

ការពិនិត្យរាងកាយទូទៅ	អាយុ	ភាពញឹកញាប់
ការពិនិត្យការស្តាប់Finger Rub Test	១៥ ឆ្នាំឡើង	ពិនិត្យ ១ដង/ឆ្នាំ
ការពិនិត្យសុជនដោយវេជ្ជបណ្ឌិត ឬបុគ្គលិកសុខាភិបាល។	៣០-៣៩ ឆ្នាំ	ពិនិត្យរាងរាល់ ៣ឆ្នាំ
	៤០-៥៤ ឆ្នាំ	ពិនិត្យរាល់ឆ្នាំ
	៥៥ ឆ្នាំឡើង	ពិនិត្យតាមហានិភ័យឬអាចមានហានិភ័យ
ការពិនិត្យភ្នែកក្រោមការត្រួតពិនិត្យរបស់គ្រូពេទ្យភ្នែក	៤០-៥៤ ឆ្នាំ	ពិនិត្យ ១ដង
ការពិនិត្យ Snellen eye Chart	៥៥ ឆ្នាំឡើង	ពិនិត្យ ១-២ ឆ្នាំ
	៥៥ ឆ្នាំឡើង	ពិនិត្យ ១ដង/ឆ្នាំ

ការពិនិត្យមន្ទីរពិសោធន៍		
ភាពពេញលេញនៃឈាម CBC	១៨-៥៤ ឆ្នាំ	ពិនិត្យ ១ដង
	៥៥-៧០ ឆ្នាំ	ពិនិត្យ ១ដង/ឆ្នាំ
ទឹកនោម UA	៥៥ ឆ្នាំឡើង	ពិនិត្យ ១ដង/ឆ្នាំ

ការធ្វើតេស្តគីមីក្នុងឈាម		
ជាតិស្ករក្នុងឈាមFBS	៣៥-៥៤ ឆ្នាំ	ពិនិត្យរាងរាល់ ៣ ឆ្នាំ
	៥៥ ឆ្នាំឡើង	ពិនិត្យ ១ដង/ឆ្នាំ
មុខងារក្រលៀន Cr	៥៥ ឆ្នាំឡើង	ពិនិត្យ ១ដង/ឆ្នាំ
ប្រភេទនៃជាតិខ្លាញ់ក្នុងឈាមTotal Cholesterol & HDL	២០ ឆ្នាំឡើង	ពិនិត្យរាងរាល់ ៥ ឆ្នាំ

ការពិនិត្យផ្សេងៗ		
ជំងឺរលាកថ្លើមHBsAg	មនុស្សកើតមុនឆ្នាំ ១៩៩២	ពិនិត្យ ១ដង
មហារីកមាត់ស្បូន; ឬ Pap Smear	៣០-៥៤ ឆ្នាំ	ពិនិត្យរាងរាល់៣ ឆ្នាំ
	៥៥ ឆ្នាំឡើង	ពិនិត្យតាមហានិភ័យឬអាចមានហានិភ័យ
មហារីកមាត់ស្បូនVia	៣០-៥៤ ឆ្នាំ	ពិនិត្យរាងរាល់ ៥ ឆ្នាំ
	៥៥ ឆ្នាំឡើង	ណែនាំពិនិត្យ Pap smear
ឈាមក្នុងលាមក FOBT	៥០ ឆ្នាំឡើង	ពិនិត្យ ១ដង/ឆ្នាំ
អិចសារែទ្រូង	១៥ ឆ្នាំឡើង	ពិនិត្យ ១ដង

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

ផ្ទាំង បង្ហាញពីដំណើរការ ករណីអ្នកបានការធានាដើម្បីស្នើសុំ

សេវាលើកកម្ពស់សុខភាព និងការការពារជំងឺ

សំណងសម្រាប់ការបាត់បង់ប្រាក់ចំណូល

ទទួលបានសំណង ៥០% នៃប្រាក់ឈ្នួល

មិនលើសពី ៩០ ថ្ងៃក្នុងមួយជង
មិនលើសពី ១៨០ ថ្ងៃក្នុងមួយឆ្នាំ
ជំងឺរ៉ាំរ៉ៃមិនលើសពី ៣៦៥ ថ្ងៃក្នុងមួយឆ្នាំ

<u>ជំងឺរ៉ាំរ៉ៃ</u>

(១) ជំងឺមហារីក (២) ជំងឺក្រលៀនរ៉ាំរ៉ៃ (៣) ជំងឺអេដស៍

(៤) ជំងឺឬរបួសខួរក្បាល សរសៃឈាមខួរក្បាល ឬបណ្តាលឱ្យខ្វិនឆ្អឹងខ្នង

(៥) ផលវិបាកនៃការបាក់ឆ្អឹង ទាំងនេះរួមមានការស្អិតជាប់ឆ្អឹងយឺត ឆ្អឹងមិនស្អិត ឆ្អឹងមិនប្រក្រតី។ ឬការបាក់ឆ្អឹង

(៦) ជំងឺ ឬអាការៈផ្សេងៗ ទាមទារការព្យាបាលជាបន្តបន្ទាប់ ដោយមិនអាចធ្វើការបន្តបានលើសពី ១៨០ ថ្ងៃ ដោយការធ្វើរោគវិនិច្ឆ័យរបស់នាយកពេទ្យ។

ថ្លៃសរីរាង្គសិប្បនិម្មិត និងឧបករណ៍វេជ្ជសាស្ត្រ

បង់តាមសេចក្តីប្រកាសរបស់គណៈកម្មាធិការវេជ្ជសាស្ត្រ យោងតាមច្បាប់សន្តិសុខសង្គម ឆ្នាំ ១៩៩០

- **ចេញផ្សាយថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០២២ ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៣**

សំបុត្របញ្ជាក់ពីពេទ្យត្រូវបញ្ជាក់អំពីតម្រូវការសម្រាប់ប្រើប្រាស់វា និងលេខកូដរបស់សរីរាង្គសិប្បនិម្មិតនិងឧបករណ៍។

២. អត្ថប្រយោជន៍ក្នុងករណីសម្រាលកូន



បង់ប្រាក់ចូលរួម ៥ ក្នុងរយៈពេល ១៥ ខែ មុនខែសម្រាលកូន។

ប្រាក់ឧបត្ថម្ភសម្រាលកូន ១៥,០០០ បាតដោយមិនកំណត់ចំនួនដង។

ទទួលបានប្រាក់ឧបត្ថម្ភ ការឈប់សម្រាកក្នុងការសម្រាលកូន ៥០% នៃប្រាក់ឈ្នួលសម្រាប់រយៈពេល ៩០ថ្ងៃ ចំនួន ២ដង (សម្រាប់តែអ្នកដែលទទួលបានការធានាជាស្ត្រី)។

ការពិនិត្យផ្ទៃពោះ និងសម្រាលកូនមិនលើស ១៥០០បាត

មិនលើស ១២ សប្តាហ៍	៥០០
ច្រើនជាង ១២ – ២០ សប្តាហ៍	៣០០
ច្រើនជាង ២០– ២៨ សប្តាហ៍	៣០០
ច្រើនជាង ២៨– ៣២ សប្តាហ៍	២០០
ច្រើនជាង ៣២ ឡើងទៅ	២០០



សំបុត្ររបស់ បុគ្គលទទួលបានការធានា ករណីមិនមានសំបុត្រ អាពាហ៍ពិពាហ៍

សំបុត្ររបស់បុគ្គលទទួលបានការធានាករណីមិនមានសំបុត្រអាពាហ៍ពិពាហ៍

១.ឈ្មោះ .....

លេខអត្តសញ្ញាណប័ណ្ណ ..... អាស័យដ្ឋានទំនាក់ទំនងផ្ទះលេខ..... ក្រុម..... ផ្លូវ..... តំបន់ ..... ស្រុក/ខ័ណ្ឌ .....

ខេត្ត .....លេខកូដតំបន់..... ទូរស័ព្ទ .....

២.ខ្ញុំរស់នៅជាមួយគ្នាជាប្តីប្រពន្ធជាមួយលោកស្រី/កញ្ញា.....ដោយបើកចំហ ប៉ុន្តែដោយគ្មានការចុះឈ្មោះអាពាហ៍ពិពាហ៍

៣.លោកស្រី/កញ្ញា.....បានសំរាលកូននៅថ្ងៃទី..... ក្នុងថ្ងៃសំរាលកូននេះ ខ្ញុំអត់មានប្រពន្ធណាទៀតដែលរៀបការស្របច្បាប់ទេ។

ខ្ញុំសូមបញ្ជាក់ថា សេចក្តីថ្លែងការណ៍ខាងលើគឺត្រឹមត្រូវ និងពិតគ្រប់ផ្នែក ដូច្នេះបានចុះហត្ថលេខាជាភស្តុតាង។

(ហត្ថលេខា).....អ្នកទទួលបានការធានា
(.....)

(ហត្ថលេខា).....ស្ត្រីដែលរស់នៅជាមួយគ្នាជាប្តីប្រពន្ធ
(.....) បើកចំហជាមួយអ្នកទទួលបានការធានារ៉ាប់រង

ហត្ថលេខា).....សាក្សី
(.....)

(ហត្ថលេខា).....សាក្សី
(.....)

ការព្រមាន ផ្នែកទី ៣៤១ នៃក្រមព្រហ្មទណ្ឌ មនុស្សបោកប្រាស់ បញ្ឆោតអ្នកដ៏ទៃដោយបង្ហាញការនិយាយមិនពិត ឬលាក់បាំងសារពិត ដែលគួរជូនដំណឹង និងតាមមធ្យោបាយបោកប្រាស់ ដូច្នេះទទួលបានទ្រព្យសម្បត្តិពីជនបោកប្រាស់ ឬជនទីបីដែលធ្វើ ដក ឬបំផ្លាញឯកសារចំណងជើង បុគ្គលនោះប្រព្រឹត្តបទល្មើសឆបោកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបីឆ្នាំ ឬពិន័យមិនលើសប្រាំមួយពាន់បាត ឬទាំងពីរ។

៣. អត្ថប្រយោជន៍ពិការភាព

ទទួលបានសំណង ៥០% នៃប្រាក់ឈ្នួល

ប្រាក់សំណងចំពោះការបាត់ចំណូល

កម្រិតស្រាល	បាត់បង់ ៣៥ - ៤៩ ភាគរយ បានសំណង ៣០ ភាគរយនៃប្រាក់ឈ្នួល រយៈពេល១៥ ឆ្នាំ
កម្រិតធ្ងន់	បាត់បង់ ៥០% ឬច្រើនជាងនេះ ទទួលបានសំណង ៥០% នៃប្រាក់ឈ្នួលពេញមួយជីវិត។

ថ្លៃរក្សាព្យាបាល

ពេទ្យរដ្ឋ	អ្នកជំងឺមិនដេកបើកវិញបានតាមការចំណាយស្តែងនឹងចាំប្រាប់/ អ្នកជំងឺដេកពេទ្យព្យាបាលបានដោយមិនបង់ប្រាក់។
ពេទ្យឯកជន	អ្នកជំងឺមិនដេក មិនលើស ២,០០០/ខែ អ្នកជំងឺដេកពេទ្យ មិនលើស ៤,០០០/ខែ

ថ្លៃរថយន្តសង្គ្រោះ/ថ្លៃរថយន្តសម្រាប់ដឹកជនពិការ ៥០០ បាតក្នុងមួយខែ

ប្រាក់សោធននិវត្តន៍អាយុចាស់ (ករណីមិនមែនជាអ្នកដែលទទួលបានការធានា)

ប្រសិនបើជនពិការស្លាប់

ថ្លៃបុណ្យសព ប្រាក់ឧបត្ថម្ភមរណភាព ដូចគ្នាចំពោះករណីស្លាប់

៤. អត្ថប្រយោជន៍ក្នុងករណីស្លាប់

បង់វិភាគទានយ៉ាងហោចណាស់ ១ ខែក្នុងរយៈពេល ៦ ខែមុនខែដែលស្លាប់

ថ្លៃបុណ្យសព ៥០,០០០ បាត

ប្រាក់ឧបត្ថម្ភមរណភាពត្រូវបានបង់ទៅឱ្យបុគ្គលដែលទូលបានការធានា បានចេញលិខិតបញ្ជាក់ពីសិទ្ធិទទួលឬទទួលមរតក

បង់ប្រាក់វិភាគទានចូលរួម ៣៦ - ១១៩ ខែ ទទួលបានប្រាក់ ២ ដង
បង់ប្រាក់វិភាគទានចូលរួមចាប់ពី១២០ ខែឡើងទៅបានទទួលប្រាក់ ៦ដង។
អ្នកដែលទទួលបានការធានា ទទួលបានសំណងសម្រាប់ការបាត់បង់ប្រាក់ចំណូល ខណៈពេលដែលអ្នកជងឺពុំរ៉ៃ ការស្លាប់មានសិទ្ធិទទួលបានថ្លៃបុណ្យសព/ប្រាក់ឧបត្ថម្ភក្នុងករណីស្លាប់។

ប្រាក់សោធននិវត្តន៍អាយុចាស់ (ក្នុងករណីស្លាប់ ត្រូវបង់ជូនអ្នកស្នងមរតកដូចខាងក្រោម)

១. ឪពុកម្តាយ
២. ប្តីឬប្រពន្ធ
៣. កូនស្របច្បាប់
៤. បុគ្គលផ្សេងទៀតដែលអ្នកទទួលបានការធានាធ្វើលិខិតបញ្ជាក់ជាបុគ្គលដែលមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភ។

ឧទាហរណ៍ឯកសារ ក្នុងករណីស្លាប់



หนังสือรับรองการเป็นผู้จัดการศพ

สถานที่.....

วันที่.....

ด้วย ○ นาย ○ นาง ○ นางสาว.....

ได้นำศพของ ○ นาย ○ นาง ○ นางสาว.....

มาบำเพ็ญกุศลที่.....ตั้งอยู่เลขที่.....หมู่ที่.....

ถนน.....ตำบล/แขวง.....

อำเภอ/เขต.....จังหวัด.....ระยะเวลา.....วัน

ตั้งแต่วันที่.....ถึงวันที่.....และ ได้ทำการ

○ ฌาปนกิจศพ ○ เก็บเศษ วันที่.....เวลา.....น.

ข้าพเจ้า.....ตำแหน่ง.....

ขอรับรองว่า ○ นาย ○ นาง ○ นางสาว.....

อยู่บ้านเลขที่.....หมู่ที่.....ถนน.....

ตำบล/แขวง.....อำเภอ/เขต.....

จังหวัด.....เป็นผู้จัดการศพแต่เพียงผู้เดียว

ลงชื่อ.....

(.....)

ตำแหน่ง.....

(ประทับตราวัด หรือภูตสถาน)



หนังสือระบุให้เป็นผู้มีสิทธิรับเงินบำเหน็จรายเดือน

เขียนที่.....

วันที่.....เดือน.....พ.ศ.....

ข้าพเจ้า นาย/นาง/นางสาว.....นามสกุล.....

อายุ.....ปี เลขประจำตัวประชาชน [ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ] เป็นผู้ประกันตน

ที่มีสิทธิได้รับประโยชน์ทดแทนกรณีชราภาพตามพระราชบัญญัติประกันสังคม พ.ศ. 2533 แก้ไขเพิ่มเติม

โดยพระราชบัญญัติประกันสังคม (ฉบับที่ 4) พ.ศ. 2558

ขอแสดงเจตนาระบุผู้มีสิทธิได้รับเงินบำเหน็จรายเดือนกรณีข้าพเจ้าถึงแก่ความตาย โดยหนังสือฉบับนี้ว่า

เมื่อข้าพเจ้าถึงแก่ความตายและยังมีสิทธิได้รับประโยชน์ทดแทนกรณีชราภาพตามมาตรา 77 ตัวตามพระราชบัญญัติ

ประกันสังคม พ.ศ.2533 ฯ ข้าพเจ้าประสงค์ให้จ่ายเงินบำเหน็จรายเดือน

นาย /นาง /นางสาว.....นามสกุล.....

เลขประจำตัวประชาชน [ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ] ที่อยู่ปัจจุบันที่สามารถติดต่อได้ เลขที่.....

หมู่ที่.....อาคาร/หมู่บ้าน.....ซอย.....ถนน.....

ตำบล/แขวง.....อำเภอ/เขต.....จังหวัด.....รหัสไปรษณีย์.....

โทรศัพท์.....โทรสาร.....โทรศัพท์เคลื่อนที่.....

หนังสือฉบับนี้ ข้าพเจ้า.....ได้แสดงเจตนาลายลักษณ์อักษรไว้

ต่อหน้าพยาน และพยานได้ลงลายมือชื่อรับรองข้อความในหนังสือต่อหน้าข้าพเจ้าแล้ว

ลงชื่อ.....ผู้แสดงเจตนา

(.....)

ลงชื่อ.....พยาน

(.....)

[ ][ ][ ][ ][ ][ ][ ][ ][ ][ ]

ลงชื่อ.....พยาน

(.....)

[ ][ ][ ][ ][ ][ ][ ][ ][ ][ ]

หมายเหตุ
- ให้ระบุเลขประจำตัวประชาชนของพยานด้วย
- ให้ผู้ประกันตน หรือผู้มีสิทธิตามหนังสือฉบับนี้ไว้ด้วย
- กรณีผู้ประกันตนมีการเปลี่ยนแปลงชื่อผู้มีสิทธิได้ทำตามหนังสือฉบับนี้ด้วย
- กรณีผู้ประกันตนประสงค์แสดงเจตนารายบุคคลให้ผู้มีสิทธิรับเงินบำเหน็จรายเดือนมากกว่า 1 คนขึ้นไป สามารถระบุสัดส่วนได้
- เมื่อผู้ประกันตนเสียชีวิตให้ผู้ที่ผู้ประกันตนมอบบุคคลให้เป็นผู้มีสิทธิยื่นคำขอรับเงินตามหนังสือฉบับนี้ไปยื่นต่อสำนักงานประกันสังคมจังหวัด/กรุงเทพมหานครที่ตนเองมีสิทธิ ณ วันที่ตนเองเสียชีวิต ภายในสองปีนับแต่วันที่ผู้ประกันตนเสียชีวิต



แบบหนังสือระบุให้เป็นผู้มีสิทธิรับเงินสงเคราะห์กรณีตาย

เขียนที่.....

วันที่.....เดือน.....พ.ศ.....

ข้าพเจ้า นาย/นาง/นางสาว.....นามสกุล.....

อายุ.....ปี เลขประจำตัวประชาชน [ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ] เป็นผู้ประกันตน

ตามพระราชบัญญัติประกันสังคม พ.ศ. 2533

ขอแสดงเจตนาระบุผู้มีสิทธิได้รับเงินสงเคราะห์กรณีข้าพเจ้าถึงแก่ความตายตามมาตรา 73 (2)

แห่งพระราชบัญญัติประกันสังคม พ.ศ. 2533 แก้ไขเพิ่มเติมโดยพระราชบัญญัติประกันสังคม (ฉบับที่ 2) พ.ศ. 253

โดยหนังสือฉบับนี้ว่า เมื่อข้าพเจ้าถึงแก่ความตาย ข้าพเจ้าประสงค์ให้จ่ายเงินสงเคราะห์แก่บุคคลธรรม.....ก

ดังมีรายชื่อต่อไปนี้

1. ชื่อ.....นามสกุล.....

เลขประจำตัวประชาชน [ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ] ให้ได้รับ.....ส่ว

โทรศัพท์.....โทรสาร.....โทรศัพท์เคลื่อนที่.....

2. ชื่อ.....นามสกุล.....

เลขประจำตัวประชาชน [ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ] ให้ได้รับ.....ส่ว

โทรศัพท์.....โทรสาร.....โทรศัพท์เคลื่อนที่.....

หนังสือฉบับนี้ ข้าพเจ้า.....ได้แสดงเจตนาลงลายมือชื่อไ

ต่อหน้าพยาน และพยานได้ลงลายมือชื่อรับรองข้อความในหนังสือต่อหน้าข้าพเจ้าแล้ว

ลงชื่อ.....ผู้แสดงเจตนา

(.....)

ลงชื่อ.....พยาน

(.....)

[ ][ ][ ][ ][ ][ ][ ][ ][ ][ ]

ลงชื่อ.....พยาน

(.....)

[ ][ ][ ][ ][ ][ ][ ][ ][ ][ ]

หมายเหตุ
1) ให้ระบุเลขประจำตัวประชาชนของพยานด้วย
2) ให้ผู้ประกันตน หรือผู้มีสิทธิตามหนังสือฉบับนี้ไว้ด้วย
3) เมื่อผู้ประกันตนเสียชีวิตให้ผู้มีสิทธิยื่นคำขอรับเงินตามหนังสือฉบับนี้ไปยื่นต่อสำนักงานประกันสังคมจังหวัดหรือสำนักงานประกันสังคมกรุงเทพมหานครที่ตนเองมีสิทธิ ณ วันที่ตนเองเสียชีวิต ภายในสองปีนับแต่วันที่ผู้ประกันตนเสียชีวิต
4) หากมีการเปลี่ยนแปลงชื่อผู้มีสิทธิให้ทำตามหนังสือฉบับที่ทำไว้ก่อนหน้า

มิตรไทย www.mitrthai.com Migrant Working Group
IOM UN MIGRATION
Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra
Swiss Agency for Development and Cooperation SDC
PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

៥. អត្ថប្រយោជន៍នៃការថែទាំកូន

បង់វិភាគទានយ៉ាងហោចណាស់ ១២ ខែក្នុងរយៈពេល ៣៦ ខែមុនពេលទទួលបានសិទ្ធិ

បង់សរុបក្នុងអត្រា ៨០០ បាត/កូនម្នាក់

រហូតដល់ ៣ នាក់ក្នុងមួយលើក (កូនស្របច្បាប់)

ពីកំណើតដល់អាយុ ៦ ឆ្នាំ។

កូនអ្នកដែលទទួលបានការធានា ពិការ/ស្លាប់សរុបនៃអត្រា ៨០០បាត / ម្នាក់។

ក្រណីស្វាមីភរិយាដែលជាអ្នកទទួលបានការធានាទាំងពីរ ពួកគេអាចជ្រើសរើសប្រើប្រាស់សិទ្ធិម្នាក់ក្នុងចំណោមពួកគេ។

***កូននឹងក្លាយជាកូនស្របច្បាប់របស់ឪពុក ចាប់ពីថ្ងៃដែលកូនកើតមក ***

ការអស់សិទ្ធិទទួលបានប្រាក់ឧបត្ថម្ភកូន

១. នៅពេលកុមារឈានដល់អាយុ ៦ ឆ្នាំ
២. ផ្តល់កូនឱ្យក្លាយជាកូនចិញ្ចឹមរបស់អ្នកដទៃ
៣. កូនស្លាប់
៤. កូនដែលទទួលបានការធានាត្រូវបញ្ចប់

ធ្វើដូចម្តេចដើម្បីក្លាយជាកូនស្របច្បាប់ យោងតាមច្បាប់របស់ឪពុក



ដើម្បីក្លាយជាកូនប្រុសស្របច្បាប់តាមច្បាប់របស់ឪពុកបំពេញតាមលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោមនេះ

១. ការចុះឈ្មោះអាពាហ៍ពិពាហ៍

២. ការចុះឈ្មោះសម្រាប់សំបុត្រកំណើត

៣. តុលាការសម្រេចថាគាត់ជាកូន

***កូននឹងក្លាយជាកូនស្របច្បាប់របស់ឪពុក ចាប់ពីថ្ងៃដែលកូនកើតមក ***

៦. អត្ថប្រយោជន៍ករណីចាស់ជរា

បង់ប្រាក់ចូលរួមចំណែក ១ - ១៧៩ ខែទទួលបានប្រាក់សោធននិវត្តន៍ (ទទួលបានប្រាក់ដុំ)

បង់ប្រាក់រួមចំណែក ១៨០ ខែឬច្រើនជាងនេះទទួលបានប្រាក់សោធននិវត្តន៍អាយុចាស់ (ប្រចាំខែ)

លក្ខខណ្ឌនៃការមានសិទ្ធិ

១. ឈានដល់អាយុ ៥៥ ឆ្នាំ, និង

២. ការបញ្ចប់នៃការដែលទទួលបានការធានា

ការផ្តល់ប្រាក់សោធននិវត្តន៍ជារាភាព

រួមចំណែកបង់ប្រាក់តិចជាង ១២ ខែ

ទទួលបានតែផ្នែករបស់អ្នកដែលទទួលបានការធានា

ការរួមចំណែកបង់ប្រាក់ពី ១២ ទៅ ១៧៩ ខែ

ទទួលបានចំណែកប្រាក់របស់អ្នកដែលទទួលការធានា + និយោជក + អត្ថប្រយោជន៍តាមអត្រាដែលបានបញ្ជាក់

ប្រាក់ឈ្នួលជាមធ្យមសម្រាប់ ៦០ ខែចុងក្រោយ X ២០%

បង់ប្រាក់វិភាគទានក្នុងករណីអាយុចាស់ឈានដល់ ១៨០ ខែ (១៥ ឆ្នាំ) = ២០%
អតិរេករាល់ ១២ ខែ បន្ថែមមួយទៀត = ១.៥%

ការបង់ប្រាក់ចូលនិវត្តន៍ ជារៀងរាល់ខែរហូតដល់ស្លាប់ ដោយបានទទួលប្រាក់តាមធានា
*** *ច្បាប់ចម្លងសៀវភៅបញ្ជីសន្សំ ឬភ្ជាប់ប្រមេដែយ ជាមួយលេខអត្តសញ្ញាណប័ណ្ណតែប៉ុណ្ណោះ ***

ឧទាហរណ៍នៃអត្រាប្រាក់ចូលនិវត្តជរាភាព

ដែលអ្នកទទួលបានការធានាទទួលបានប្រចាំខែយោងតាមរយៈពេលនៃការបង់ប្រាក់ចូលរួម។

ចំនួនខែការចូលរួមបង់វិភាគទាន(បង់ចំនួនដង)	ភាគរយនៃប្រាក់ឈ្នួលជាមធ្យម	ប្រាក់ឈ្នួលជាមធ្យមសម្រាប់រយៈពេល ៦០ ខែចុងក្រោយ					
		៤,៨០០	៥,០០០	៨,០០០	១០,០០០	១២,០០០	១៥,០០០
		ប្រាក់និវត្តន៍បានទទួល	ប្រាក់និវត្តន៍បានទទួល	ប្រាក់និវត្តន៍បានទទួល	ប្រាក់និវត្តន៍បានទទួល	ប្រាក់និវត្តន៍បានទទួល	ប្រាក់និវត្តន៍បានទទួល
១៨០	២០%	៩៦០	១,០០០	១,៦០០	២,០០០	២,៤០០	៣,០០០
១៩២	២១.៥%	១,០៣២	១,០៧៥	១,៧២០	២,១៥០	២,៥៨០	៣,២២៥
២០៤	២៣ %	១,១០៤	១,១៥០	១,៨៤០	២,៣០០	២,៧៦០	៣,៤៥០
២១៦	២៤.៥%	១,១៧៦	១,២២៥	១,៩៦០	២,៤៥០	២,៩៤០	៣,៦៧៥
២២៨	២៦ %	១,២៤៨	១,៣០០	២,០៨០	២,៦០០	៣,១២០	៣,៩០០
២៤០	២៧.៥%	១,៣២០	១,៣៧៥	២,២០០	២,៧៥០	៣,៣០០	៤,១២៥
២៥២	២៩%	១,៣៩២	១,៤៥០	២,៣២០	២,៩០០	៣,៤៨០	៤,៣៥០
២៦៤	៣០.៥ %	១,៤៦៤	១,៥២៥	២,៤៤០	៣,០៥០	៣,៦៦០	៤,៥៧៥
២៧៦	៣២ %	១,៥៣៦	១,៦០០	២,៥៦០	៣,២០០	៣,៨៤០	៤,៨០០
២៨៨	៣៣.៥ %	១,៦០៨	១,៦៧៥	២,៦៨០	៣,៣៥០	៤,០២០	៥,០២៥
៣០០	៣៥ %	១,៦៨០	១,៧៥០	២,៨០០	៣,៥០០	៤,២០០	៥,២៥០

អ្វីដែលត្រូវដឹង

សម្រាប់អ្នកទទួលបានការធានា មានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍ចាស់ជរា

ត្រឡប់មកជាអ្នកដែលទទួលបានការធានាវិញ នោះត្រូវឈប់ទទួលប្រាក់ចូលនិវត្តន៍

ប្រសិនបើការបញ្ចប់ការជាអ្នកទទួលបានការធានា នោះនឹងទទួលបានប្រាក់ចូលនិវត្តន៍ចាស់ជរាម្តងទៀត

ស្លាប់ពេលទទួលប្រាក់សោធននិវត្តន៍ក្នុងរយៈពេល ៦០ ខែ

អនុញ្ញាតឱ្យអ្នកទទួលមរតកទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែដែលនៅសល់រហូតដល់ ៦០ ខែ (មានប្រសិទ្ធភាពចាប់ពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២២)

បានទទួលប្រាក់សោធននិវត្តន៍ ត្រឡប់មកជាអ្នកទទួលបានការធានាហើយបានស្លាប់ក្នុងរយៈពេល ៦០ ខែ

អនុញ្ញាតឱ្យអ្នកទទួលមរតកទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែដែលនៅសល់រហូតដល់ ៦០ ខែ (មានប្រសិទ្ធភាពចាប់ពីថ្ងៃទី ២៩ខែមេសា ឆ្នាំ ២០២២)និងទទួលបានប្រាក់សោធនិវត្តន៍ដែលត្រលប់មកជាការទទួលបានការធានា

ស្លាប់ពេលទទួលប្រាក់សោធននិវត្តន៍ប៉ុន្តែមិនទាន់គ្រប់ ៦០ ខែ

ហើយប្រាក់សោធននិវត្តន៍ចាស់ជរានៅសល់គឺតិចជាង ១០ ខែ ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ១០ ដង (ក្នុងករណីអ្នកមានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍មុនថ្ងៃទី ២៩ ខែមេសាឆ្នាំ ២០២២ តែប៉ុណ្ណោះ)

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

ករណីអ្នកមានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍បានស្លាប់

អ្នកស្នងមរតកដែលមានសិទ្ធិ

១. កូនស្របច្បាប់ លើកលែងតែកូនចិញ្ចឹម ឬកូនដែលត្រូវបានទទួលដោយអ្នកផ្សេង នឹងទទួលបាន ២ ចំណែក បើមានកូនបីនាក់ ឬលើសពីនេះ នឹងទទួលបាន ៣ ចំណែក។

២. ប្តី ឬប្រពន្ធ ទទួលបាន ១ ចំណែក

៣. ឪពុកម្តាយ ឬឪពុក ឬម្តាយដែលនៅរស់ នឹងទទួលបាន ១ ចំណែក។

៤. បុគ្គល ដែលអ្នកបានទទួលការធានាធ្វើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរថាមានសិទ្ធិ នោះទទួលបាន ១ ចំណែក។

ក្នុងករណីដែលគ្មានអ្នកទទួលមរតក ឬគ្មានបុគ្គលដែលធ្វើលិខិតបញ្ជាក់ថាជាអ្នកមានសិទ្ធិ

សិទ្ធិនោះនឹងផ្តល់ទៅដល់សាច់ញាតិតាមលំដាប់ ដែលទទួលបានចំណែកស្មើគ្នា។

១. បងប្អូនបង្កើតឪពុកម្តាយដូចគ្នា។

២. បងប្អូនបង្កើតដែលមានឪពុក ឬម្តាយដូចគ្នា។

៣. ជីដូនជីតា

៤. ពូ មីង អ៊ំ

៧. អត្ថប្រយោជន៍អត់ការងារធ្វើ

បង់ប្រាក់ចូលរួម ៦ ក្នុងរយៈពេល ១៥ ខែ មុនពេលគ្មានការងារធ្វើជាមួយថៅកែចុងក្រោយ។

១. ការលាលែង/ការបញ្ចប់កិច្ចសន្យាការងារ ទទួលបាន ៣០% នៃប្រាក់ឈ្នួលមិនលើសពី ៩០ ថ្ងៃ/ឆ្នាំប្រតិទិន
២. ការបញ្ចប់ការងារ ទទួលបាន ៥០% នៃប្រាក់ឈ្នួល មិនលើសពី ១៨០ ថ្ងៃ/ឆ្នាំប្រតិទិន
៣. ភាពអត់ការងារធ្វើដោយសារគ្រោះធម្មជាតិ ទទួលបាន ៥០% នៃប្រាក់ឈ្នួលមិនលើសពី ១៨០ ថ្ងៃ។
៤. ភាពអត់ការងារធ្វើដោយសារឧបទ្ទវហេតុកើតឡើងពីការផ្ទុះឡើងនៃជំងឺឆ្លង ទទួលបានប្រាក់ឈ្នួល ៥០% មិនលើសពី ៩០ ថ្ងៃ។
៥. ដកចេញ / បណ្តេញចេញ បដិសេធ / មិនបង់ប្រាក់។

លក្ខខណ្ឌនៃការទទួលបានសិទ្ធិ (ក្នុងករណីលាលែង / បញ្ចប់ការងារ)

១. បានចុះឈ្មោះនៅក្នុងប្រព័ន្ធព័ត៌មាននៃការិយាល័យការងាររដ្ឋ http://e-service.doe.go.th
២. អាចអនុវត្តការងារសមស្របដែលរដ្ឋផ្តល់។
៣. មិនត្រូវបដិសេធកម្មសិក្សាទេ។
៤. ត្រូវតែរាយការណ៍ទៅការិយាល័យការងារយ៉ាងហោចណាស់ម្តងក្នុងមួយខែ បើមិនបានរាយការណ៍គឺមិនបានទទួលប្រាក់ឈ្នួល។
៥. មិនត្រូវបានបណ្តេញចេញដោយសារតែការប្រព្រឹត្តខុសចំពោះនិយោជក

ទាមទារប្រាក់អត្ថប្រយោជន៍អត់ការងារធ្វើដោយសារឧបទ្ទវហេតុ ដែលអ្នកទទួលការជានាមិនបានចាកចេញពីការងារ ដូច្នេះមិនចាំបាច់ចុះឈ្មោះនៅលើគេហទំព័ររបស់នាយកដ្ឋានការងារនោះទេ។

ការទាមទារអត្ថប្រយោជន៍

- ដាក់ពាក្យស្នើសុំសំណងក្នុងរយៈពេល ២ ឆ្នាំគិតចាប់ពីថ្ងៃទទួលបានសិទ្ធិ
- ទំនាក់ទំនងដើម្បីទទួលបានប្រាក់ក្នុងរយៈពេល ២ ឆ្នាំគិតចាប់ពីថ្ងៃជូនដំណឹងដើម្បីទទួលប្រាក់។
- បន្ទាប់ពីចាកចេញពីការងារ ពួកគេនឹងមានសិទ្ធិក្នុងករណីឈឺ សម្រាលកូន ពិការ និងស្លាប់រយៈពេល ៦ ខែទៀត (ផ្នែកទី ៣៨ វគ្គ ៤១)។
- សិទ្ធិប្តឹងឧទ្ធរណ៍លើដីកានេះក្នុងរយៈពេល ៣០ ថ្ងៃចាប់ពីថ្ងៃទទួលបានដីកា។
- ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសាលាឧទ្ធរណ៍ មានសិទ្ធិនាំសំណុំរឿងទៅតុលាការការងារក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃដឹងលទ្ធផលនៃបណ្តឹងសាទុក្ខ

អ្នកដែលទទួលការធានាស្មុគ្រចិត្ត តាមមាត្រា ៣៩



គុណសម្បត្តិរបស់បេក្ខជន

១. ធ្លាប់ជាអ្នកដែលទទួលបានការធានារ៉ាប់រងតាមមាត្រា ៣៣ ហើយបានបង់ប្រាក់រួមចំណែកមិនតិចជាង ១២ ខែ។

២. ត្រូវដាក់ពាក្យស្នើសុំជាអ្នកដែលទទួលបានការធានារ៉ាប់រង ដោយដាក់ពាក្យសុំតាមមាត្រាទី ៣៩ ក្នុងរយៈពេល ៦ ខែគិតចាប់ពីថ្ងៃបញ្ចប់ការងារ។

អ្នកដែលបានទទួលការធានាក្រោមមាត្រាទី ៣៩ នឹងបញ្ចប់នៅពេល

១. ស្លាប់

២. លាចេញឈប់

៣. ត្រលប់មកជាអ្នកដែលទទួលបានការធានា តាមមាត្រា ៣៣

៤. អាក់ខានការបង់ប្រាក់ចូលរួម ៣ ខែជាប់ៗគ្នា

៥. ក្នុងរយៈ ១២ខែ បង់ប្រាក់ចូលរួមមិនគ្រប់ ៩ ខែ

ឯកសារគាំទ្រសម្រាប់ការទាមទារអត្ថប្រយោជន៍

១. ថ្លៃព្យាបាល

សំបុត្របញ្ជាក់ពីពេទ្យ វិក័យប័ត្រ ច្បាប់ចម្លងនៃទំព័រទីមួយនៃសៀវភៅធនាគារ

២. បាត់បង់ប្រាក់ចំណូល តាមមាត្រា ៣៣

សំបុត្របញ្ជាក់ពីពេទ្យ សំបុត្របញ្ជាក់ពីថៅកែ ស្ថិតិថ្ងៃលាសំរាក (ប្រសិនបើមាន)

បាត់បង់ប្រាក់ចំណូល តាមមាត្រា ៣៩

សំបុត្របញ្ជាក់ពីពេទ្យ ច្បាប់ចម្លងទំព័រទីមួយនៃសៀវភៅធនាគារ

៣.ថ្លៃសរីរាង្គ/ឧបករណ៍សិប្បនិម្មិត

សំបុត្របញ្ជាក់ពីពេទ្យ (បញ្ជាក់តម្រូវការប្រើប្រាស់) វិក័យប័ត្រ ច្បាប់ចម្លងទំព័រសៀវភៅធនាគារ។

៤. ពិការភាព

សំបុត្របញ្ជាក់ពីពេទ្យ វិក័យប័ត្រ ច្បាប់ចម្លងនៃកំណត់ត្រាវេជ្ជសាស្ត្រ ច្បាប់ចម្លងទំព័រសៀវភៅធនាគារ។

៥. ការសម្រាលកូន +ប្រាក់ឧបត្ថម្ភកុមារ

ច្បាប់ចម្លងសំបុត្រកំណើត , ច្បាប់ចម្លងសំបុត្រអាពាហ៍ពិពាហ៍ , សំបុត្រអ្នកដែលទទួលបានការធានាក្នុងករណីគ្មានសំបុត្រអាពាហ៍ពិពាហ៍ (សម្រាប់សិទ្ធិបុរស) ច្បាប់ចម្លងនៃទំព័រទីមួយនៃសៀវភៅគណនីធនាគារ។

៦. ស្លាប់ ប្រាក់ចូលនិវត្តន៍ក្នុងករណីស្លាប់

ច្បាប់ចម្លងសំបុត្រមរណភាព សៀវភៅរៀបចំពិធីបុណ្យសព ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ/សំបុត្រកំណើត ច្បាប់ចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់អ្នកស្លាប់ហើយអ្នកមានសិទ្ធិ។

៧.ជរាភាព

ច្បាប់ចម្លងទំព័រមុខសៀវភៅធនាគារ

៨.គ្មានការងារ

ច្បាប់ចម្លងទំព័រមុខសៀវភៅធនាគារ

វិធីដើម្បីទទួលបានអត្ថប្រយោជន៍ទទួលប្រាក់

បានតាមធនាគារ ឬទទួលប្រាក់តាមវេរលុយ។

- ធនាគារកសិករ
- ធនាគារអាយុធ្យា
- ធានាគារបាងកក
- ធនាគារពាណិជ្ជសាយ៉ាម
- ធនាគារឥស្លាមថៃ
- ធនាគារក្រុងថៃ
- ធានាគារ ធីអឹមប៊ីថាញ់ណៈឆាត
- ធនាគារយោធាថៃ
- ធនាគារ ស៊ីអាយអិមប៊ី ថៃ
- ធនាគារសន្សំប្រាក់
- ធនាគារកសិកម្ម និងសហករណ៍កសិកម្ម

ចំណេះដឹងទាក់ទងនឹងមូលនិធិសំណង

ច្បាប់ប្រាក់សំណង ១៩៩៤ បានធ្វើការកែប្រែបន្ថែមដោយ ច្បាប់ប្រាក់សំណង ច្បាប់ទី ២ ឆ្នាំ២០១៨

គោលបំណង

ដើម្បីជួយបន្ថយភាពទុក្កលំបាកដល់កូនឈ្នួលដែលជួបគ្រោះថ្នាក់ ឬឈឺដែលកើតចេញពីការធ្វើការអោយថៅកែ ឬការពារផលប្រយោជន៍របស់និយោជក

ច្បាប់ប្រាក់សំណង ១៩៩៤ បានដាក់អោយប្រើ ចាប់ពីថ្ងៃ ១ កក្កដា ១៩៩៤)

ច្បាប់ប្រាក់សំណងច្បាប់ទី២ ២០១៨ បានដាក់អោយប្រើ ចាប់ពីថ្ងៃ ៩ ធ្នូ ២០១៨

កូនឈ្នួលដែលដោយទទួលបានការគាំពារពីមូលនិធិសំណង

១. កូនឈ្នួលនៃគ្រឹះស្ថានដែលមានកូនឈ្នួល បុគ្គលិកលើសពី ១ នាក់។

២. បុគ្គលិកកិច្ចសន្យាបណ្តោះអាសន្នរបស់កិបាលគ្រប់ប្រភេទ។

៣. បុគ្គលិកនៃអង្គការអន្តរជាតិ រដ្ឋាភិបាលបរទេសដែលធ្វើការនៅក្នុងប្រទេស។

៤. បុគ្គលិកនៃសហគ្រាសសេដ្ឋកិច្ចមិនរកប្រាក់ចំណេញ។

៥. កម្មករ នេសាទ ព្រៃឈើ ចិញ្ចឹមសត្វ ចំការ។

មូលនិធិសំណង សម្រាប់បុគ្គលិកទាំងអស់ៗ

មូលនិធិសំណង គឺជាមូលនិធិដែលបានបង្កើតឡើង ដើម្បីទូទាត់សំណងដល់បុគ្គលិកជំនួសនិយោជក នៅពេលដែលពួកគាត់ទទួលរងគ្រោះថ្នាក់ឬជំងឺ ពិការ ដែលអាចស្លាប់ ឬការបាត់ខ្លួនដោយសារការធ្វើការងារឱ្យនិយោជក ដោយមិនគិតពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងប៉ុន្តែនឹងពិនិត្យមើលមូលហេតុនៃការរងគ្រោះដោយគ្រោះថ្នាក់ ឬជំងឺ ។ ដូចនេះនិយោជកត្រូវទទួលខុសត្រូវលើការបង់រំភាគទានចូលរួមតែម្នាក់ឯងតែប៉ុណ្ណោះដល់មូលនិធ។

គ្រោះថ្នាក់

និយោជិតត្រូវបានរងរបួសទាំងផ្លូវកាយ ឬផ្លូវចិត្ត។ ឬការស្លាប់ដោយសារការងារ ឬដើម្បីការពារផលប្រយោជន៍របស់និយោជក ឬតាមបញ្ជារបស់និយោជក

ឈឺ

ជំងឺរបស់បុគ្គលិកកម្មករ ឬមរណភាពដោយសារជំងឺដែលកើតចេញពីលក្ខខណ្ឌឬសភាពនៃការងារ ឬដោយសារតែការងារ។

ការបាត់ខ្លួន

ការបាត់ខ្លួនរបស់បុគ្គលិកកម្មករ ក្នុងពេលបំពេញការងារ ឬគោរពតាមការណែនាំរបស់ ថៅកែក្រុមហ៊ុន ដែលមានហេតុផលសមហេតុផលក្នុងការជឿថាបុគ្គលិកកម្មករ បានស្លាប់ នេះគឺសម្រាប់រយៈពេលមិនតិចជាង ១២០ ថ្ងៃគិតចាប់ពីថ្ងៃកើតហេតុ។



មូលនិធិសំណង សម្រាប់បុគ្គលិកទាំងអស់ៗ

បានទទួលសិទ្ធិនេះភ្លាមៗចាប់ពីថ្ងៃដំបូង ដែលធ្វើការឱ្យថៅកែឬក្រុមហ៊ុននោះ

ដោយសារតែ

១. បុគ្គលិកធ្វើការឱ្យថៅកែឬក្រុមហ៊ុន។
២. បុគ្គលិកជាអ្នកការពារផលប្រយោជន៍។
៣. បុគ្គលិកធ្វើការតាមការណែនាំរបស់ថៅកែឬក្រុមហ៊ុន។
៤. អសន្តិសុខនៅកន្លែងធ្វើការ

ពេលជួបគ្រោះថ្នាក់ ឬឈឺកើតចេញពីការងារតើត្រូវទៅព្យាបាលដោយរបៀបណា?

បុគ្គលិកឬកម្មករត្រូវតែទទួលការព្យាបាលភ្លាមៗនៅក្នុងមន្ទីរពេទ្យណាមួយទាំងរដ្ឋនិងឯកជន។

ចែកជា ២ ករណី

១. មន្ទីរពេទ្យ ក.ថ ៤៤ (មិនគិតថ្លៃ) បង្កើតការបើកប្រាក់ជាមួយមូលនិធិសំណង។
២. ចាយប្រាក់ខ្លួនឯងជាមុនសិន (អាចទទួលបានប្រាក់មកវិញក្នុងរយៈពេល ៩០ ថ្ងៃគិតចាប់ពីថ្ងៃដែលយើងបង់ប្រាក់ខ្លួនឯង)។

មូលនិធិសំណង សម្រាប់បុគ្គលិកទាំងអស់

១. ថៅកែឬក្រុមហ៊ុនដាក់ការជូនដំណឹងអំពីគ្រោះថ្នាក់ ការឈឺ ឬការបាត់ខ្លួន (ក.ច .១៦)

នៅការិយាល័យសន្តិសុខសង្គមនៃតំបន់ដែលកម្មករធ្វើការ ឬកន្លែងណាដែលពួកគាត់មានទីលំនៅក្នុងរយៈពេល ១៥ ថ្ងៃគិតចាប់ពីថ្ងៃដែលថៅកែឬក្រុមហ៊ុនបានដឹង ឬគួរតែដឹងពីគ្រោះថ្នាក់ (មាត្រា ៤៨)។

២. កម្មករ បុគ្គលិក ឬអ្នកដែលមានសិទ្ធិដាក់ពាក្យសុំសំណង (ក.ច.១៦)

នៅការិយាល័យសន្តិសុខសង្គមនៃតំបន់ដែលពួកគាត់ធ្វើការ ឬកន្លែងណាដែលថៅកែឬក្រុមហ៊ុនមានទីលំនៅក្នុងរយៈពេល ១៨០ ថ្ងៃគិតចាប់ពីថ្ងៃមានរបួស ឬជំងឺ ឬការបាត់ខ្លួន (ផ្នែកទី ៤៩)។

(ប្រសិនបើកម្មករបុគ្គលិកឈឺ ឬទទួលរងពីជំងឺការងារបន្ទាប់ពីការបញ្ចប់កិច្ចសន្យាការងារអាចដាក់ពាក្យបណ្តឹងក្នុងរយៈពេល ២ ឆ្នាំគិតចាប់ពីថ្ងៃដែលដឹងខ្លួនថាមានជំងឺ)។

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE



ករណីពិគ្រោះថ្នាក់ដោយសារតែការងារ តាមរយៈប្រព័ន្ធ E-Compensate



www.sso.go.th
ប្រធានបទ sso e – service ជ្រើសរើសស្ថានប្រកបមុខរបរ

ជ្រើសរើសមូលនិធិសំណង ដើម្បីចូល e-compensate



ជ្រើសរើសប្រព័ន្ធ e-compensate

អត្ថប្រយោជន៍គឺ កាត់បន្ថយដំហានស្នុគស្នាញ/ធ្វើការនិងចួយបានរហ័ស/អាចធ្វើឯងផ្ទាត់បាន។

អត្ថប្រយោជន៍សំណង ដែលកម្មករ បុគ្គលិកនឹង ទទួលបាន

១. ការរក្សាព្យាបាល (មាត្រា ១៣)

២. សំណង (មាត្រា ១៨)

៣. ថ្លៃបុណ្យសព (មាត្រា ១៦, មាត្រា ១៧)

៤. ថ្លៃសេវាស្ថានីតិសម្បទា (មាត្រា ១៥)

មូលនិធិសំណង សម្រាប់បុគ្គលិកទាំងអស់

ការចំណាយរក្សាព្យាបាលគ្រោះថ្នាក់ ១ ដង

កម្មករឬបុគ្គលិកមានសិទ្ធិទទួលបានថ្លៃព្យាបាលក្នុងចំនួនទឹកប្រាក់ដែលបានបង់ពិតតាមតម្រូវការជាក់ស្តែង។

ច្បាប់ក្រសួងកំណត់អត្រាអោយថៅកែឬក្រុមហ៊ុនជាអ្នកចេញថ្លៃព្យាបាល
ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០២០

បញ្ចប់ការព្យាបាល (មន្ទីរពេទ្យរដ្ឋ)

- ១,០០០,០០០ បាត
- ៥០០,០០០ បាត
- ៣០០,០០០ បាត
- ១០០,០០០ បាត
- ៥០,០០០ បាត



បន្ទប់, អាហារនិងថ្លៃសៅរ៍ថៃទាំ ១,៣០០ បាតក្នុងមួយថ្ងៃ

២. សំណង

២.១ សំណងក្នុងករណីសម្រាករក្សាខ្លួន

បុគ្គលិកឈប់សម្រាកសម្រាប់ការព្យាបាលតាមការណែនាំរបស់វេជ្ជបណ្ឌិត ហើយពិតជាឈប់យោងទៅតាមសំបុត្រពេទ្យ ទទួលបានសំណង ៧០% នៃប្រាក់ឈ្នួលប្រចាំខែ មិនលើស១,៤០០០ បាតក្នុងមួយខែ (ថ្លៃឈ្នួលខ្ពស់បំផុត ២០,០០០បាត) ចាប់ពី ១ ថ្ងៃ ជាសរុបមិនលើសពី ១ ឆ្នាំ។

២.២ សំណងសម្រាប់ការបាត់បង់សមត្ថភាពការងារ

សំណង ៧០% នៃប្រាក់ឈ្នួលប្រចាំខែ រយៈពេលសំណងគឺ ១០ឆ្នាំ ការបាត់បង់ ១% ស្មើនឹងសំណង ២ខែ។

លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ

បញ្ចប់ការព្យាបាល / សរីរាង្គមានស្ថេរភាព គ្មានការផ្លាស់ប្តូរ / ១ ឆ្នាំ (តាំងពីចាប់ផ្តើមព្យាបាល)

២.៣ សំណងករណីពិការភាព

ទទួល៖

សំណង ៧០% នៃប្រាក់ឈ្នួលប្រចាំខែរយៈពេលសំណងពេញមួយជីវិតស្លាប់ក្នុងរយៈពេល ១០ ឆ្នាំដោយទទួលបានថ្លៃបុណ្យសពនិងសំណងរួមគ្នាមិនលើសពី ១០ ឆ្នាំ។

២. សំណង

២.៤ សំណងក្នុងករណីមរណភាពឬការបាត់ខ្លួន

"អ្នកដែលមានសិទ្ធិ" ទទួលបានសំណង ៧០% នៃប្រាក់ឈ្នួលប្រចាំខែសម្រាប់រយៈពេល ១០ ឆ្នាំ។ បុគ្គលដែលមានសិទ្ធិរួមមាន:

១. មាតាឬបិតាស្របច្បាប់
២. ប្តីឬប្រពន្ធស្របច្បាប់
៣. កូនអាយុក្រោម ១៨ ឆ្នាំ
៤. កូនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលនៅតែសិក្សាក្នុងកម្រិតមិនខ្ពស់ជាងបរិញ្ញាបត្រ ត្រូវបានទទួលចំណែក ពេញមួយរយៈដែលគាត់កំពុងសិក្សា។
៥. កូនចាប់ពីអាយុ ១៨ ឆ្នាំ និងពិការ ឬផ្លូវចិត្ត ពិការភាពដែលពឹងផ្អែកលើបុគ្គលិក កម្មករ មុនពេលពួកគាតស្លាប់ ឬបាត់ខ្លួន។
៦. កូនរបស់បុគ្គលិក កម្មករ កើតក្នុងរយៈពេល ៣១០ ថ្ងៃគិតចាប់ពីថ្ងៃស្លាប់ ឬកាលបរិច្ឆេទនៃគ្រោះថ្នាក់របស់បុគ្គលិកកម្មករ មានសិទ្ធិទទួលបានសំណងចាប់ពីថ្ងៃដែលកូនគាត់កើត។
៧. បើគ្មានមនុស្សខាងលើ អ្នកនៅក្នុងបន្ទុករបស់បុគ្គលិកកម្មករមុនពេលស្លាប់ ឬបាត់ខ្លួន គឺជាអ្នកមានសិទ្ធិ។ ប៉ុន្តែ អ្នកនៅក្នុងបន្ទុកបែបនេះ ត្រូវតែរងទុក្ខដោយសារតែខ្វះការគាំទ្រពីបុគ្គលិកកម្មរដែលបានស្លាប់ ឬបាត់ខ្លួន។

អ្នកមានសិទ្ធិ បាត់បង់នូវសិទ្ធិទទួលបានសំណងនៅពេល

- ស្លាប់
- ប្តីឬប្រពន្ធ រៀបការជាប្តីប្រពន្ធជាមួយស្ត្រីឬបុរសផ្សេងទៀត។
- មានអាយុ ១៨ ឆ្នាំ មិនបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ។

****យកផ្នែកនៅសល់មកគិតជាមធ្យមនិងផ្តល់អោយអ្នកមានសិទ្ធិដែលនៅសល់។ ****

៣. ថ្លៃធ្វើបុណ្យសព

ផ្តល់ថ្លៃធ្វើបុណ្យសព ៥០,០០០ បាតដល់អ្នកចាត់ចែងពិធីបុណ្យ

ច្បាប់ក្រសួង ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០២១ កំណត់អត្រាថ្លៃបុណ្យសពដែលថៅកែឬក្រុមហ៊ុនត្រូវបង់អោយ។

៤. ថ្លៃស្ថារនីតិសម្បទាការងារ

ថ្នាំស្ថារនីតិសម្បទា

មិនលើសពី ២៤,០០០ បាត

សម្ភារៈ និងបរិក្ខារឱសថសម្រាប់ស្ថារនីតិសម្បទា

មិនលើសពី ១៦០,០០០ បាត

ការព្យាបាលនិងការវះកាត់

មិនលើសពី ៤០,០០០ បាត និងបង់ប្រាក់លើសពី ១៤០,០០០ បាត ដោយអោយគណៈកម្មាធិការវេជ្ជសាស្ត្រជាអ្នកពិចារណា។

ផ្នែករៀនវិជ្ជាជីវៈ

មិនលើសពី ២៤,០០០ បាត

ច្បាប់ស្តីពីថ្លៃស្ថារនីតិសម្បទាការងារ ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០២០ដែលនិយោជកជាអ្នកបង់ចំណាយ។

៤. ផ្លែស្តារនីតិសម្បទាការងារ

សកម្មភាពពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រ

សកម្មភាពព្យាបាលរាងកាយ

សកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈ

សេវាស្តារនីតិសម្បទាផ្លូវចិត្ត និងសង្គម

ការពិគ្រោះយោបល់បុគ្គល

សកម្មភាពកីឡា

តន្ត្រីនិងការសម្តែង

ជំណើរកំសាន្ត

មជ្ឈមណ្ឌលស្ថានីតិសម្បទាកម្មករ

បង្កើតឡើងដោយការិយាល័យសន្តិសុខសង្គម ដើម្បីផ្តល់សេវាស្ថានីតិសម្បទាយ៉ាងទូលំទូលាយ បុគ្គលិកកម្មករអាចទទួលបានសេវាស្ថានីតិសម្បទាចំនួន ៥ ដូចខាងក្រោម៖

មណ្ឌលស្ថានីតិសម្បទាបុគ្គលិកកម្មករតំបន់ ៣ ខេត្តឈៀងម៉ៃ

មណ្ឌលស្ថានីតិសម្បទាបុគ្គលិកកម្មករតំបន់ ៤ ខេត្តខនកែន

មណ្ឌលស្ថានីតិសម្បទាបុគ្គលិកកម្មករតំបន់ ១ ខេត្តប៉ាធុមថានី

មណ្ឌលស្ថានីតិសម្បទាបុគ្គលិកកម្មករតំបន់ ២ ខេត្តរ៉ាក់យ៉ាង

មណ្ឌលស្ថានីតិសម្បទាបុគ្គលិកកម្មករតំបន់ ៥ ខេត្តសុងក្លា

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

កន្លែងដែលអាចទទួលប្រាក់បាន

នៅការិយាល័យសន្តិសុខសង្គម
រៀតាមតាមបុស្ត៍
សៃកតាមប្រៃសណីយ៍
ផ្ញើរទៅគណនីធនាគារខាងក្រោម

ធានាការក្រុងថៃ ធានាក្រុងស្រ៊ី ធានាគារអមសីន ធានាគារ ថ.ក.ស

បណ្តឹងឧទ្ធរណ៍

បុគ្គលិកឬកម្មករដែលមិនយល់ស្របនឹងការសម្រេចចិត្តរបស់មន្ត្រី មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃទទួលស្គាល់សេចក្តីសម្រេច។

ប្រសិនបើមិនពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការមូលនិធិនោះពួកគេមានសិទ្ធិនាំយកសំណុំរឿងនេះទៅតុលាការការងារក្នុងរយៈពេល ៣០ ថ្ងៃចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។

និយោជកមិនចាំបាច់បង់ប្រាក់សំណងដល់និយោជិតនោះទេ។

ប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀន រហូតដល់បង្កគ្រោះថ្នាក់និយោជិតបង្កគ្រោះថ្នាក់ដោយចេតនា ឬអនុញ្ញាតឱ្យអ្នកដទៃបង្កគ្រោះថ្នាក់ដល់ពួកគេ

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT



ឯកសារគាំទ្រសម្រាប់ការបំពេញទម្រង់របាយការណ៍គ្រោះថ្នាក់

១. ទម្រង់របាយការណ៍ស្តីពីគ្រោះថ្នាក់ ជំងឺ ឬការបាត់ខ្លួន (ក.ច.១៦)
២. សំបុត្របញ្ជាក់ពីពេទ្យ
៣. លិខិតណែនាំរបស់និយោជិត (កខ. ៤៤) ក្នុងករណីបង់ប្រាក់ដោយខ្លួនឯង ត្រូវភ្ជាប់បង្កាន់ដៃបង់ប្រាក់មកជាមួយ។
៤. ច្បាប់ចម្លងកសុតាងនៃការចូលរួមម៉ោងធ្វើការ
៥. កសុតាងនៃការទូទាត់ប្រាក់ឈ្នួល (ក្នុងករណីស្នើសុំការឈប់សម្រាកព្យាបាល)។
៦. ថតចំលងឯកសារចុះបញ្ជីយានយន្តដែលហេតុ
៧. លិខិតកត់ត្រាប៉ូលីស
៨. ផែនទីកន្លែងកើតហេតុ

ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍

សម្រាប់ជនបរទេស ត្រូវមានឯកសារបន្ថែមដូចខាងក្រោម៖

១. ច្បាប់ចម្លងប៉ាស្ព័រ
២. ច្បាប់ចម្លងវីសា
៣. ច្បាប់ចម្លងប័ណ្ណការងារ (ប័ណ្ណការងារ)
៤. ច្បាប់ចម្លងប័ណ្ណស៊ីជម្ពូ

ចំណាំ៖ បញ្ជូនទម្រង់របួសគ្រោះថ្នាក់ (ក.ច១៦) តែម្តងគត់ អាចទទួលបានអត្ថប្រយោជន៍គ្រប់ករណីទាំងអស់។

มิตรไทย www.mitrthai.com Migrant Working Group IOM UN MIGRATION Schweizerische Eidgenossenschaft Confédération suisse Confederazione Svizzera Confederaziun svizra Swiss Agency for Development and Cooperation SDC PROMISE POVERTY REDUCTION THROUGH SAFE MIGRATION, SKILLS DEVELOPMENT AND ENHANCED JOB PLACEMENT

បញ្ហាដែលបានជួបប្រទះក្នុងការបញ្ជូនដីកសារ

១. ក.ថ ១៦ បំពេញសេចក្តីលម្អិតមិនច្បាស់លាស់ដូចជា

- ក្នុងករណីសំណង ក្នុងករណីអវត្តមានពីការងារ ប្រាក់ឈ្នួលមិនបានបញ្ជាក់ ប្រាក់ឈ្នួលមិនត្រូវគ្នានឹងការផ្ទេរប្រាក់ទេ។
- ពេលវេលាគ្រោះថ្នាក់របស់បុគ្គលិក កម្មករ មិនត្រូវគ្នានឹងម៉ោងធ្វើការធម្មតាទេ។
- មូលហេតុគ្រោះថ្នាក់មិនត្រូវនឹងលិខិតបញ្ជាក់ពីគ្រូពេទ្យ ។
- បុគ្គលិក កម្មករ និងថៅកែ ក្រុមហ៊ុន មិនចុះហត្ថលេខាលើ ក.ថ ១៦ ។



២. ថៅកែ ក្រុមហ៊ុន ឬអ្នកដែលបានទទួលអំណាចជំនួសចុះហត្ថលេខាលើ ក.ថ ១៦ និង ក.ថ ៤៤ មិនមែនជាហត្ថលេខីដែលមានការអនុញ្ញាត ដូចដែលបានបង្ហាញជាមួយការិយាល័យសន្តិសុខសង្គមនោះទេ។

៣. ថៅកែ ក្រុមហ៊ុន មិនចុះឈ្មោះបុគ្គលិក កម្មករក្នុងរយៈពេលកំណត់នោះទេ។